**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..០២៧៥...ស.ខ.៧

ថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត**

**កម្មវត្ថុ:** ការបង្កើនការប្រុងប្រយ័ត្ន និងមានវិធានការបង្ការការឆ្លងជំងឺគ្រុនផ្តាសាយបក្សី H5N1។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** ជ្រាបថា ស្របពេលជាមួយការជំរុញការអប់រំផ្សព្វផ្សាយព័ត៌មាន និងវិធានការការពារជំងឺ COVID-19 ជូនដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងជាមួយគ្នានេះ ដោយផ្អែកតាមព័ត៌មានពីខេត្តត្រា ភាគខាងត្បូងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ មានផ្ទុះជំងឺផ្តាគ្រុនសាយបក្សី H5N1 ហើយអាជ្ញាធរវៀតណាមបានកំទេចសត្វមាន់ប្រមាណ ៥ម៉ឺន ៥ពាន់ក្បាល ក្រសួងសុខាភិបាល សូម **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត** បង្កើនការប្រុងប្រយ័ត្ន និងធ្វើការណែនាំអប់រំប្រជាពលរដ្ឋដើម្បីបង្ការទប់ស្កាត់ ការឆ្លងជំងឺគ្រុនផ្តាសាយបក្សី H5N1 មកមនុស្ស ជាពិសេសនៅតាមបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម ដូចជា: ខេត្តកណ្តាល ស្វាយរៀង ព្រៃវែង ត្បូងឃ្មុំ កំពត រតនគីរី មណ្ឌលគីរី កែប និងតាកែវ ៖ ដោយមិនត្រូវទទួលទានសត្វបក្សីឈឺ ឬងាប់ និងរាល់បសុបក្សីសម្រាប់បរិភោគ ត្រូវចំអិនឲ្យបានឆ្អិនល្អ។ ត្រូវលាងដៃឲ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកមុនពេលបរិភោគ និងបន្ទាប់ពីប៉ះពាល់ផ្ទាល់ជាមួយបសុបក្សី។ បើបុគ្គលណាម្នាក់មានគ្រុនក្តៅលើសពី ៣៨.៥ អង្សាសេ ក្អក ពិបាកដកដង្ហើម និងមានមានប្រវត្តិប៉ះពាល់ជាមួយបសុបក្សី ឈឺ ឬងាប់ ក្នុងអំឡុងពេល១៤ថ្ងៃ មុនចេញរោគសញ្ញា សូមទំនាក់ទំនងទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ឬទូរស័ព្ទលេខ: ០១២ ៤៨៨ ៩៨១ / ០១២ ៨៣៦ ៨៦[illegible]៨។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត យកចិត្តទុកដាក់ និងចាត់វិធានការអប់រំផ្សព្វផ្សាយការបង្ការការឆ្លងជំងឺគ្រុនផ្តាសាយបក្សី H5N1 នៅក្នុងសហគមន៍ដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូម ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ម៉ម_ប៊ុនហេង**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩